ធ្វើការរួមគ្នាដើម្បីភាពប្រសើរឡើង Working Together for Positive Change

វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា

The NGO Forum on Cambodia

លេខៈ ០៤១ ......../NGOF/២០១៧

**សូមគោរពជូន**

**ឯកឧត្តមបណ្ឌិត ទី សុគន្ធ**

**រដ្ឋលេខាធិការនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**កម្មវត្ថុៈ ស្នើសុំចូលរួមយោបល់លើសេចក្តីព្រាងច្បាប់ស្តីពីដីកសិកម្ម ចុងក្រោយលើកទី៦ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ ២០១៦**

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ តាងនាឲ្យបណ្តាញអភិវឌ្ឍន៍សន្តិសុខ និងសុវត្ថិភាពស្បៀងនៅកម្ពុជា នៃវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា សូមសំដែងនូវការគោរពនិងកោតសរសើរដ៏ក្រៃលែងដល់ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ និង អគ្គនាយកដ្ឋានកសិកម្ម ដែលបានដឹកនាំរៀបចំកិច្ចពិភាក្សាពិគ្រោះយោបល់ទៅលើសេចក្តីព្រាងច្បាប់ដីកសិកម្មលើកទី៦នេះដោយទទួលបានជោគជ័យ។

យើងខ្ញុំសូមគោរពជម្រាបជូន **ឯកឧត្តមបណ្ឌិត** មេត្តាជ្រាបថា បន្ទាប់ពីបញ្ចប់សិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិកាលពីខែធ្នូឆ្នាំ២០១៦រួចមក ក្រុមការងារបណ្តាញអភិវឌ្ឍន៍សន្តិសុខ និងសុវត្ថិភាពស្បៀងនៅកម្ពុជាបានបន្តពិនិត្យមើលលើសេចក្តីព្រាងច្បាប់ដីកសិកម្មដែលមានទីប្រឹក្សាបរទេស ខ្មែរ និង ការប្រមូលផ្តុំគំនិតរួមគ្នាផងដែរពីតំណាងកសិករនិងអ្នកទទួលលជាក់ស្តែងនៅទីវាលដើម្បីធ្វើយ៉ាងផ្តល់ធាតុចូលសំខាន់ៗដល់ក្រសួងដែលកំពុងពិនិត្យនិងកែសម្រួលលើសេចក្តីព្រាងច្បាប់ដីកសិកម្ម ដែលជាផលប្រយោជន៍ដល់កសិករនៅទីជនបទ។

ខ្ញុំបាទសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ **ឯកឧត្តមបណ្ឌិត** ដែលជានិច្ចជាកាលតែងតែផ្តល់ការសហការល្អជាមួយវេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា និង បានផ្តល់ឱកាសសមាជិកបណ្តាញបានចូលរួមក្នុងកិច្ចការផ្សេងៗដែលរៀបចំឡើងដោយក្រសួង។

អាស្រ័យដូចបានគោរពជូនខាងលើ សូម **ឯកឧត្តមបណ្ឌិត** មេត្តាពិនិត្យពិចារណាលើមតិយោបល់ដូចមានភ្ជាប់មកជាមួយ។

សូម **ឯកឧត្តមបណ្ឌិត** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែមេសា ឆ្នាំ២០១៧

**នាយកប្រតិបត្តិ**

**បណ្ឌិត តឹក វណ្ណារ៉ា**

ជូនភ្ជាប់ជាមួយនូវៈ

-សេចក្តីសង្ខេបមតិយោបល់អំពីសេចក្តីព្រាងច្បាប់ដីកសិកម្ម លើកទី៦ ១ច្បាប់

-ការចូលរួមយោបល់លម្អិតទៅលើច្បាប់ដីកសិកម្ម១ច្បាប់

ផ្ទះលេខ ៩-១១ ផ្លូវ ៤៧៦ ទួលទំពូង១ ភ្នំពេញ ប្រអប់សំបុត្រលេខ ២២៩៥ ភ្នំពេញ-៣ # 9-11, St 476, Toul Tompoung1, Phnom Penh, P.O. Box 2295 Phnom Penh-3

Tel: (855) 23 214 429 Fax: (855) 23 994 063 E-mail: ngoforum@ngoforum.org.kh Website: www.ngoforum.org.kh

វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា
The NGO Forum on Cambodia

# សេចក្តីសង្ខេបមតិយោបល់អំពីសេចក្តីព្រាងច្បាប់ដីកសិកម្មលើកទី៦

## ១.ការចូលរួមមតិយោបល់ជារួម

| ជំពូក | មាត្រា | ខ្លឹមសារដើមនៃច្បាប់ | សំណើរសុំការកែសម្រួល | មូលហេតុនៃការស្នើ |
|---|---|---|---|---|
| ៣ | ១១ | គោលនយោបាយជាតិធនធានដីកសិកម្ម ត្រូវឆ្លងកាត់ដំណើរពិគ្រោះយោបល់ដោយមានការចូលរួមពីភាគីពាក់ព័ន្ធ និងត្រូវរៀបចំដោយផ្អែកតាមដ្ឋានទិន្នន័យធនធានដីកសិកម្ម សក្តានុពលនិងតម្រូវការក្នុងក្របខណ្ឌនៃការប្រើប្រាស់ដី សម្រាប់ចក្ខុវិស័យអភិវឌ្ឍន៍សង្គម សេដ្ឋកិច្ចជាតិ និងវិសាលភាពនៃការអភិវឌ្ឍវិស័យកសិកម្ម | យើងខ្ញុំសូមស្នើ ជាដំបូងគួរអនុម័តគោលនយោបាយ បន្ទាប់មកអនុម័តផែនការ ហើយអនុម័តច្បាប់។ វិធីសាស្ត្របែបនេះ អាចសម្រេចបាននូវអ្វីដែលយើងខ្ញុំបានស្នើឡើងក្នុងចំណុចខាងលើ | អង្គការនិងកសិករដែលបានផ្តល់យោបល់ទៅលើសេចក្តីព្រាងច្បាប់នេះបានសម្តែងនូវការភ័យខ្លាចនិងជំទាស់នឹងសេចក្តីព្រាងច្បាប់នេះ។ នេះគឺដោយសារតែលក្ខខណ្ឌតម្រូវ ទោសទណ្ឌ និងការជំរុញអនុវត្តន៍ច្បាប់ទាំងអស់នោះ។ ពួកគាត់យល់ឃើញថា វាធ្វើឱ្យពួកគាត់ទទួលរងផលប៉ះពាល់ ហើយមិនមែនជាការជួយដល់ពួកគាត់ទេ។ ពួកគាត់បានមើលឃើញបញ្ហាមួយចំនួន ដែលមិនពាក់ព័ន្ធនឹងការគ្រប់គ្រងដីកសិកម្មថាជាបញ្ហា |
| ៣ | ១២ | ផែនការយុទ្ធសាស្ត្រជាតិគ្រប់គ្រងនិងប្រើប្រាស់ធនធានដីកសិកម្ម ស្របតាមគោលនយោបាយជាតិធនធានដី កសិកម្ម | | |

| | | | | |
|---|---|---|---|---|
| | | | | បន្ទាន់ជាងសេចក្តីព្រាងច្បាប់នេះ។ ឧទាហរណ៍ រដ្ឋាភិបាលគួរធ្វើឱ្យពួកគាត់ទទួលបានឥណទានការប្រាក់ទាប គួរជួយទិញដំណាំដែលលើសពីតម្រូវការ គួរអន្តរាគមន៍ដើម្បីការពារគ្រួសារកសិករនៅពេលដែលសុវត្ថិភាពនៃការកាន់កាប់ដីរបស់ពួកគាត់ ទទួលរងការគំរាមកំហែងពីអ្នកមានអំណាច គួរកសាងប្រព័ន្ធធារាសាស្ត្របន្ថែម គួរផ្តល់ដីបន្ថែមទៀតដល់គ្រួសារកសិករ និង គួរផ្តល់ការណែនាំផ្នែកបច្ចេកទេសឱ្យកាន់តែច្រើននិងប្រសើរជាងមុន ព្រមទាំងផ្តល់ជំនួយដល់គ្រួសារកសិករ។ |
| ៥ | ៣០ ទំព័រ ១៧ | ៣.អនុវត្តការចុះបញ្ជីប្រើប្រាស់ដីកសិកម្មចំពោះដីកសិកម្មប្រមូលផ្តុំ ឬក្បាលដីរួមដែលបានបង្កើត កាន់កាប់ និងប្រើប្រាស់ក្រោមសហគមន៍កសិកម្ម តំបន់អភិវឌ្ឍន៍កសិកម្ម និង ក្រោមភតិសន្យាជួល។ | អនុវត្តការចុះបញ្ជីប្រើប្រាស់ដីកសិកម្មចំពោះតំបន់អភិវឌ្ឍន៍កសិកម្ម និង ក្រោមភតិសន្យាជួល។ | យើងខ្ញុំជឿជាក់ថា ចំណុចនេះ នឹងមានន័យជាការបញ្ជាក់បន្ថែមឱ្យកាន់តែច្បាស់ថា ផ្នែកទាក់ទងនឹងតំបន់អភិវឌ្ឍន៍កសិកម្ម មិនទាក់ទងនឹងសហគមន៍ជនជាតិដើមភាគតិចទេ។ |
| ៥ | ៣៥ ទំព័រ ១៩ | រាជរដ្ឋាភិបាលមានសិទ្ធសម្រេចឲ្យក្រសួងទទួលបន្ទុកវិស័យកសិកម្ម ចាត់វិធានការចំពោះដីកសិកម្មដែលទុកចោលទំនេរដើម្បីប្រើប្រាស់ជាបណ្តោះអាសន្នសម្រាប់ | រាជរដ្ឋាភិបាលមានសិទ្ធសម្រេចឲ្យក្រសួងទទួលបន្ទុកវិស័យកសិកម្ម ចាត់វិធានការចំពោះដីកសិកម្មដែលទុកចោលទំនេរដើម្បីប្រើប្រាស់ជាបណ្តោះអាសន្ន | |

| | | | | |
|---|---|---|---|---|
| | | ប្រយោជន៍ សាធារណៈក្រោមគោលបំណងផលិតកម្មកសិកម្ម នៅក្នុងរយៈពេលចាប់ពី០១(មួយ)ឆ្នាំឡើងទៅ រហូតដល់ពេលមានការស្នើសុំពីកម្មសិទ្ធិករឬម្ចាស់ដីនោះជាថ្មី ដើម្បីប្រើប្រាស់ដីកសិកម្មជាកម្មសិទ្ធិរបស់ខ្លួន ក្រោមផលិតកម្មកសិកម្មឡើងវិញ ។ | សម្រាប់ប្រយោជន៍ សាធារណៈក្រោមគោលបំណងផលិតកម្មកសិកម្ម នៅក្នុងរយៈពេលចាប់ពី០១(មួយ)ឆ្នាំឡើងទៅ រហូតដល់ពេលមានការស្នើសុំពីកម្មសិទ្ធិករឬម្ចាស់ដីនោះជាថ្មី ដើម្បីប្រើប្រាស់ដីកសិកម្មជាកម្មសិទ្ធិរបស់ខ្លួន ក្រោមផលិតកម្មកសិកម្មឡើងវិញ ។បទប្បញ្ញត្តិនៅក្នុងមាត្រានេះមិនពាក់ព័ន្ធនឹង ដីកសិកម្មតាមប្រពៃណីរបស់សហគមន៍ជនជាតិដើមភាគតិចទេ។ | |
| ៥ | ៣៧ ទំព័រ ១៩ | រដ្ឋធានាសិទ្ធិប្រើប្រាស់ដីកសិកម្មបែបប្រពៃណីរបស់សហគមន៍ជនជាតិដើមភាគតិចក្រោមបទប្បញ្ញត្តិនិងនីតិវិធីនៃច្បាប់នេះ និងបទដ្ឋានច្បាប់ពាក់ព័ន្ធជាធរមាន។ ការអនុវត្តកសិកម្មពនេចរដោយសហគមន៍ជនជាតិដើមភាគតិចត្រូវបានទទួលស្គាល់ដោយច្បាប់នេះ ជាការប្រើប្រាស់ដីសម្រាប់គោលបំណងកសិកម្ម ដែលត្រូវរៀបចំ និង | សុំលុបចោលបទប្បញ្ញត្តិស្តីពីការចាត់ថ្នាក់ដី (ដីកសិកម្មបម្រុង) សម្រាប់ជនជាតិដើមភាគតិច នៅក្នុងមាត្រា៣៧នេះ | សហគមន៍ជនជាតិដើមភាគតិច កំពុងប្រឈមនឹងបទប្បញ្ញត្តិរបស់រដ្ឋាភិបាលជាច្រើនរួចស្រាប់ហើយ។ វប្បធម៌ និងកម្រិតអប់រំរបស់ពួកគាត់ ធ្វើឱ្យពួកគាត់មានការលំបាកក្នុងការដោះស្រាយបញ្ហានេះខ្លាំងណាស់។ មានបទប្បញ្ញត្តិផ្លូវច្បាប់និងកម្មវិធីជាច្រើនរួចស្រាប់ហើយទាក់ទងនឹងការចាត់ថ្នាក់[1] ការចុះបញ្ជី[2] ការបម្រុងទុក[3] |

[1] នៅពេលក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ ចាប់ផ្តើមដំណើរការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច ការអនុវត្តនាពេលបច្ចុប្បន្ននេះ បើយោងតាមអនុក្រឹត្យ គឺត្រូវ**ធ្វើអនុបយោគ**ពីដីសាធារណៈរបស់រដ្ឋ ទៅជាដីឯកជនរបស់រដ្ឋ ទៅលើគ្រប់ដីដែលក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់នឹងត្រូវចុះបញ្ជី

| | | | | |
|---|---|---|---|---|
| | | ចាត់ថ្នាក់ ជាផ្ទៃដីកសិកម្មបម្រុងនៃធនធានដីកសិកម្ម សម្រាប់កសិកម្មប្រពៃណីរបស់សហគមន៍ជនជាតិដើមភាគតិច។ | | និងការគ្រប់គ្រង[4]ដីសហគមន៍ជនជាតិដើមភាគតិច។ យើងខ្ញុំស្នើសុំឱ្យមានការធ្វើវិសោធនកម្មទៅលើសេចក្តីព្រាងច្បាប់នេះ ដោយ លុបចោលនូវរាល់ប្រភេទនៃការចាត់ថ្នាក់ថ្មីៗ ការចុះបញ្ជី និងបទប្បញ្ញត្តិជាទូទៅទាក់ទងនឹងសហគមន៍ជនជាតិដើមភាគតិច។ |
| ៥ | ៣៨ ទំព័រ ១៩ | ក្រសួងទទួលបន្ទុកវិស័យកសិកម្ម ត្រូវសហការនិងសម្របសម្រួលជាមួយក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ រដ្ឋបាលថ្នាក់ក្រោមជាតិ និងសហគមន៍ជនជាតិដើមភាគតិចដើម្បីកំណត់ និងចាត់ថ្នាក់ផ្ទៃដីកសិកម្មបម្រុងសម្រាប់កសិកម្មប្រពៃណីរបស់សហគមន៍ជនជាតិដើមភាគតិច។ | សុំលុបចោលបទប្បញ្ញត្តិស្តីពីការចាត់ថ្នាក់ដី (ដីកសិកម្មបម្រុង) និងការចុះបញ្ជីសម្រាប់ជនជាតិដើមភាគតិច នៅក្នុងមាត្រា៣៨នេះ | |
| ៥ | ៣៩ | ដើម្បីធានានិរន្តរភាពនៃការប្រើប្រាស់ដីកសិកម្មប្រពៃណីរបស់សហគមន៍ជនជាតិ | ដើម្បីធានានិរន្តរភាពនៃការប្រើប្រាស់ដីកសិកម្មប្រពៃណីរបស់សហគមន៍ជនជាតិ | |

[2] អនុក្រឹត្យ៨៣ (២០០៩) ស្តីពីនីតិវិធីក្នុងការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច ចែងអំពី **ការចុះបញ្ជី**ប្រភេទទាំងប្រាំនៃដិសហគមន៍ជនជាតិដើមភាគតិច។ ប្រភេទទាំងនេះ រួមមានដីកសិកម្មរបស់សហគមន៍ទាំងអស់។ បច្ចុប្បន្ននេះ អនុក្រឹត្យនោះ កំពុងត្រូវបានអនុវត្ត។ សូមកត់សម្គាល់ថា បច្ចុប្បន្ននេះ ក្រសួងបរិស្ថានកំពុងព្រាងក្រមបរិស្ថាននិងធនធានធម្មជាតិនៃព្រះរាជាណាចក្រកម្ពុជា ដែលរួមមានបទប្បញ្ញត្តិចែងអំពីប្រភេទមួយចំនួននៃប័ណ្ណកម្មសិទ្ធិសហគមន៍ដែលចេញដោយក្រសួងបរិស្ថាន។

[3] ច្បាប់ភូមិបាលឆ្នាំ២០០១ មាត្រា២៥ ចែងថា "ដីសហគមន៍ជនជាតិដើមភាគតិច មិនមែនមានតែដីដែលបានដាំដុះដាក់ស្តែងនោះទេ ប៉ុន្តែមានដី**បម្រុង**ចាំបាច់ក្នុងការដូរវេនដំណាំថែមទៀត ..."។ អនុក្រឹត្យឆ្នាំ២០០៩ ស្តីពីនីតិវិធីក្នុងការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច ចែងក្នុងមាត្រា៤ ថា "ដី**បម្រុង**ចាំបាច់សម្រាប់កសិកម្មវិលជុំ ឬដី**បម្រុង**ក្នុងការដូរវេនដំណាំ ឬដីកសិកម្មពនេចរ សំដៅទៅលើដីដែលសហគមន៍ជនជាតិដើមភាគតិចប្រើពីមុនមកជាស្រែចំការ ឬកន្លែងដាំដុះសម្រាប់កសិកម្មវិលជុំតាមបែបប្រពៃណី។ មាត្រា ៦ នៃអនុក្រឹត្យនោះ ចែងអំពីការផ្តល់ប័ណ្ណកម្មសិទ្ធិដីទាំងនោះ។(បន្ថែមពណ៌ខ្មៅដិត)។

[4] ច្បាប់ភូមិបាលឆ្នាំ២០០១ មាត្រា២៣ ចែងថា "សហគមន៍ជនជាតិដើមភាគតិច គឺជាក្រុមមនុស្សដែលរស់នៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជាដែលសមាជិកទាំងអស់បង្ហាញនៃការឯកភាពនៃជាតិពន្ធុ សង្គម វប្បធម៌ និងសេដ្ឋកិច្ច ប្រតិបត្តិរបៀបរស់នៅតាមប្រពៃណីនិងដាំដុះលើដីដែលខ្លួនកាន់កាប់ទៅតាមក្បួនខ្នាតទំនៀមទំលាប់នៃការប្រើប្រាស់ជាសមូហភាព។ ក្នុងពេលរងចាំការកំណត់ខាងផ្លូវច្បាប់នូវលក្ខន្តិកៈរបស់សហគមណ៍ ក្រុមដែលមានជាក់ស្តែងមកទល់បច្ចុប្បន្ននេះនឹងបន្តគ្រប់គ្រងសហគមន៍និងអចលនវត្ថុរបស់ខ្លួនតាមប្រពៃណី ហើយត្រូវអនុវត្តតាមបញ្ញត្តិនៃច្បាប់នេះ។ (បន្ថែមពណ៌ខ្មៅដិត)

| | | | | |
|---|---|---|---|---|
| | | ដើមភាគតិច ក្រសួងទទួលបន្ទុកវិស័យកសិកម្ម ត្រូវជំរុញការអនុវត្តកម្មវិធី ដូចខាងក្រោម | ដើមភាគតិច ក្រសួងទទួលបន្ទុកវិស័យកសិកម្ម ត្រូវជំរុញការអនុវត្តកម្មវិធី ដូចខាងក្រោម។ រាល់កម្មវិធីទាំងនេះ គ្រាន់តែជាការណែនាំប៉ុណ្ណោះ ដែលសហគមន៍ជនជាតិដើមភាគតិច មានសេរីភាពក្នុងការទទួលយក ឬមិនទទួលយក។ ការណែនាំនេះ នឹងរួមបញ្ចូល មិនត្រឹមតែអ្វីដែលក្រសួងជឿថាសហគមន៍ជនជាតិដើមភាគតិច គួរធ្វើតែប៉ុណ្ណោះទេ ប៉ុន្តែវាក៏មានបញ្ចូលនូវអ្វីដែលសហគមន៍ជនជាតិដើមភាគតិច មិនគួរធ្វើដែរ។ | |
| ៥ | ៤០ ទំព័រ ២០ | ការគ្រប់គ្រងដីកសិកម្មប្រពៃណីរបស់សហគមន៍ជនជាតិដើមភាគតិចត្រូវកំណត់ដោយប្រកាសរបស់ក្រសួងទទួលបន្ទុកវិស័យកសិកម្ម | សុំលុបមាត្រានេះ | |
| ៥ | ៤២ ទំព័រ ២១ | (២)-ដីកម្មសិទ្ធឯកជនផ្ទាល់ ដីកម្មសិទ្ធសមូហភាព | ដីកម្មសិទ្ធឯកជនផ្ទាល់ ដីកម្មសិទ្ធសមូហភាព ដីដែលរដ្ឋផ្តល់ជាអំណោយដល់អ្នកគ្មានដី និងអ្នកក្រមានដីតិចតួច ឬដីសម្បទានសង្គមកិច្ច។<br>(៥)-ដីកសិកម្មមិនប្រើប្រាស់ ដែលពីមុនជាផ្នែកដែលស្ថិតនៅក្នុងកិច្ចសន្យាសម្បទាន។ | ដើម្បីអនុញ្ញាតឱ្យមានការបែងចែកផ្តល់ដីក្នុងសម្បទានដីសេដ្ឋកិច្ចដែលបានកាត់ចេញឬដែលបានលុបចោល ដល់ប្រជាជនក្រីក្រ។<br>អ្វីដែលយើងខ្ញុំស្នើឡើងសម្រាប់ចំណុចនេះ ដើម្បីមានការពង្រីកចំណុចនេះ ដើម្បីបញ្ចូលដីដែលជាអតីតសម្បទានដី |

| | | | | |
|---|---|---|---|---|
| | | | | សេដ្ឋកិច្ច ដែលត្រូវបែងចែកដើម្បីបង្កើតជាសម្បទានដីសង្គមកិច្ច។ ច្បាប់ភូមិបាលឆ្នាំ២០០១ មាត្រា៨៣ អាចជាមូលដ្ឋានផ្លូវច្បាប់សម្រាប់ការផ្តល់ជាអំណោយនេះ។ នេះជាមូលដ្ឋានផ្លូវច្បាប់សម្រាប់ការផ្តល់ជាអំណោយ នៅក្នុងកម្មវិធីបទបញ្ជា០១ របស់សម្តេចនាយករដ្ឋមន្ត្រី។ |
| ៥ | ៤២ ទំព័រ ២១ | មិនមានខ្លឹមសារដើមទេដោយស្នើសុំបន្ថែម | សម្បទានដីសង្គមកិច្ច និងការផ្តល់អំណោយដីដល់អ្នកក្រីក្រ ដែលធ្វើឡើងដើម្បីបង្កើត តំបន់អភិវឌ្ឍន៍កសិកម្មនៅលើអតីតដីសម្បទាន ។ វាអាចពាក់ព័ន្ធនឹង ការបង្កើតគម្រោងនានា ដែលមានលំនៅដ្ឋាន ហេដ្ឋារចនាសម្ព័ន្ធ ការបណ្តុះបណ្តាល និងទម្រង់ជំនួយផ្សេងៗទៀត។ វាអាចរួមមានគម្រោងដែលអ្នកទទួលបានដី មានផ្ទះនៅជិតនោះរួចហើយ និងមានសម្ភារៈ និងសមត្ថភាពដាំដុះរួចហើយ ប៉ុន្តែពួកគេនៅខ្វះខាតមិនទាន់មានដីគ្រប់គ្រាន់នៅឡើយ។ | ស្នើសុំឱ្យមានការព្រាងមាត្រាថ្មីមួយទៀតដែលពិចារណាទៅលើកសិករមានដីតិចតួចដែលកំពុងរស់នៅជិតអតីតសម្បទានដីសេដ្ឋកិច្ច។ ប្រជាជនទាំងនេះ អាចត្រូវការតែដីធ្លីតែប៉ុណ្ណោះ ហើយពួកគាត់អាចមិនត្រូវការរបស់ផ្សេងទៀតដែលត្រូវមាននៅក្នុងកញ្ចប់នៃការបង្កើតសម្បទានដីសង្គមកិច្ចដូចជា ផ្ទះ ហេដ្ឋារចនាសម្ព័ន្ធ ការបណ្តុះបណ្តាលជំនាញដាំដុះ ជាដើមនោះទេ។ |
| ៥ | ៤៥ ទំព័រ | ដីកសិកម្មក្រោមកិច្ចព្រមព្រៀងសម្បទានត្រូវបានកំណត់ចំពោះដីរដ្ឋដែលបានធ្វើ | បន្ថែមបន្ទះវិធីមួយដែលរដ្ឋាភិបាលធានាទៅលើចំណុចនេះ គឺតាមរយៈការកាត់ | |

| | | | | |
|---|---|---|---|---|
| | ២២ | សម្បទានដោយរាជរដ្ឋាភិបាលក្រោមកិច្ចព្រមព្រៀងសម្បទានដីសេដ្ឋកិច្ចឬកិច្ចព្រមព្រៀងសម្បទានផ្សេងទៀត ដើម្បីប្រើប្រាស់រយៈពេលវែងក្នុងក្របខណ្ឌនៃការវិនិយោគផលិតកម្មកសិកម្ម កសិឧស្សាហកម្ម ឬគម្រោងអភិវឌ្ឍន៍ផ្សេងទៀតក្រោមគោលបំណងផលិតកម្មកសិកម្ម។ រាជរដ្ឋាភិបាលធានាការប្រើប្រាស់ដីកសិកម្មក្រោមកិច្ចព្រមព្រៀមសម្បទាន មិនស្ថិតនៅក្រោមទំនាស់ផលប្រយោជន៍របស់សហគមន៍មូលដ្ឋានឡើយ។ | ចេញពីតំបន់សម្បទាននូវដីធ្លីទាំងឡាយណា ដែលកាន់កាប់ដោយគ្រួសារកសិករក្នុងរយៈពេលយ៉ាងហោចណាស់មួយឆ្នាំមុនពេលផ្តល់សម្បទាននោះ ឬ ដែលកាន់កាប់ដោយសហគមន៍ជនជាតិដើមភាគតិច។ ដីទាំងនេះ ត្រូវកាត់ចេញមុនចុះហត្ថលេខាលើកិច្ចសន្យាផ្តល់សម្បទាន។ ប្រសិនបើកិច្ចសន្យាត្រូវបានចុះហត្ថលេខារួចរាល់ហើយនោះ រដ្ឋាភិបាលត្រូវពិនិត្យមើលកិច្ចសន្យានោះនិងច្បាប់ពាក់ព័ន្ធ ដើម្បីកំណត់ថាតើ វាជាការស្របច្បាប់ឬទេដែលដីទាំងនេះ ត្រូវកាត់ចេញនៅពេលនេះ។ នៅពេលដែលតំបន់សម្បទានត្រូវបានចុះបញ្ជីដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ហើយនោះ ដីដែលកាត់ចេញសម្រាប់គ្រួសារកសិករ និងសហគមន៍ជនជាតិដើមភាគតិច ក៏នឹងត្រូវបានចុះបញ្ជីដែរ។ | |
| ៧ | ៨៥<br>ទំព័រ<br>៣៨ | រាជរដ្ឋាភិបាលមានសិទ្ធិសម្រេចផ្ទេរដីរដ្ឋ ទោះស្ថិតនៅក្រោមដែនសមត្ថកិច្ចរបស់ក្រសួងឬស្ថាប័នណាមួយក្តី មកជាធនធានដីកសិកម្មក្រោមគោលបំណងអភិវឌ្ឍន៍ | <u>**បន្ថែមបន្ត**</u>៖ ការផ្ទេរ និងការធ្វើអនុបយោគទាំងនេះ មិនត្រូវពាក់ព័ន្ធនឹងដីដែលបានចាត់ថ្នាក់រួចហើយ ឬមិនត្រូវពាក់ព័ន្ធនឹងដីដែលបានកំណត់ ជាដីសាធារណៈរបស់ | អសុវត្ថិភាពនៃការកាន់កាប់ដី គឺជាបញ្ហាធ្ងន់ធ្ងរមួយសម្រាប់សហគមន៍ជនជាតិដើមភាគតិច។ ប្រធានបទពាក់ព័ន្ធមួយ គឺការប្រើប្រាស់ដីសាធារណៈរបស់រដ្ឋ |

| | | | | |
|---|---|---|---|---|
| | | ផលិតកម្មកសិកម្មតាម រយៈកិច្ចព្រមព្រៀងសម្បទាន ឬគម្រោងអភិវឌ្ឍន៍កសិកម្មរយៈពេលវែង ដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ នឹងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។<br>ដីរដ្ឋ ដែលត្រូវផ្ទេរក្រោមគោលបំណងនៃមាត្រានេះ ត្រូវរំសាយចំណាត់ថ្នាក់ប្រើប្រាស់ដើម មកស្ថិតនៅក្រោមចំណាត់ថ្នាក់ធនធានដីកសិកម្មក្រោមដែនសមត្ថកិច្ចគ្រប់គ្រងរបស់ក្រសួងទទួលបន្ទុកវិស័យកសិកម្ម និងត្រូវចុះបញ្ជីប្រើប្រាស់ដីកសិកម្ម ស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ។ | រដ្ឋ ក្រោមច្បាប់ភូមិបាល ឬតាមបទប្បញ្ញត្តិនៃច្បាប់ពាក់ព័ន្ធផ្សេងៗទៀត។ ជាទូទៅ កិច្ចសន្យាសម្បទាន ឬគម្រោងអភិវឌ្ឍន៍កសិកម្មរយៈពេលវែង មិនត្រូវទទួលបានការអនុញ្ញាត នៅលើដីដែលត្រូវធ្វើអនុបយោគ ឬផ្លាស់ប្តូរតាមវិធីណាមួយពីដីសាធារណៈរបស់រដ្ឋ ក្នុងគោលបំណងសម្រាប់កិច្ចព្រមព្រៀងនិងគម្រោងដែលអាចធ្វើទៅបានតាមផ្លូវច្បាប់ឡើយ។ | សម្រាប់សម្បទានដីសេដ្ឋកិច្ច និងសម្រាប់ការអភិវឌ្ឍឯកជនខ្នាតធំ។ ទំនាក់ទំនងនេះ មានការពាក់ព័ន្ធជាមួយនឹងដីប្រពៃណីរបស់សហគមន៍ជនជាតិដើមភាគតិច ដែលជារឿយៗគឺជាដីសាធារណៈរបស់រដ្ឋ។ ប្រជាជនដែលមិនមែនជាជនជាតិដើមភាគតិចជាច្រើន ក៏បានចូលទៅប្រមូលអនុផលព្រៃឈើនៅក្នុងព្រៃដែលជាទូទៅជាដីសាធារណៈរបស់រដ្ឋ។ ដើម្បីការពារសុវត្ថិភាពនៃការកាន់កាប់ដីឱ្យបានកាន់តែប្រសើរសម្រាប់សហគមន៍ជនជាតិដើមភាគតិច និងដើម្បីការពារសមត្ថភាពរបស់មនុស្សទាំងអស់ ក្នុងការចូលទៅប្រមូលអនុផលព្រៃឈើនៅក្នុងព្រៃ។ |
| ១០ | ចាប់ពី<br>៩៥<br>ដល់<br>១០២<br>ទំព័រ<br>៤២<br>ដល់ | | សុំកែប្រែ វិធីសាស្ត្រជាមូលដ្ឋាននៃសេចក្តីព្រាងច្បាប់នេះ ពីវិធាននិងទោសប្បញ្ញត្តិឱ្យទៅជាការផ្តល់ជំនួយ ការណែនាំ និងការលើកទឹកចិត្តវិញ។<br>គួរកែសម្រួលឡើងវិញក្នុងផ្នែកស្តីពីទោសប្បញ្ញត្តិ និងការជំរុញអនុវត្តន៍ច្បាប់ ឱ្យមានការលុបចោលនូវទោសប្បញ្ញត្តិជា | សម្រាប់កសិករខ្នាតតូចទាំងអស់ដែលយើងខ្ញុំបានពិគ្រោះយោបល់ជាមួយបានបង្ហាញពីកង្វល់យ៉ាងខ្លាំងទៅលើវិធាននិងទោសប្បញ្ញត្តិ ជាច្រើនដែលសេចក្តីព្រាងច្បាប់បានដាក់ចេញ។ ក្នុងន័យនេះ យើងខ្ញុំបានកត់សម្គាល់ជាពិសេសទៅលើជំពូក ១០ ស្តីពីភ្នាក់ងារដីកសិកម្មនិងការជំរុញ |

| | | | | |
|---|---|---|---|---|
| | ៤៥ | | ច្រើន ជាពិសេស ទៅលើចំណុចដូចជាការសម្រេចចិត្តត្រូវដាំដំណាំអ្វី ការទុកដីចោលឱ្យទំនេរ។ល។ | អនុវត្តន៍ច្បាប់។ កសិករចង់បានវិធីសាស្ត្រមួយ ដែលពឹងផ្អែកទៅលើក្រសួងក្នុងការផ្តល់ការណែនាំបច្ចេកទេស ការអប់រំនិងការលើកទឹកចិត្តជាវិជ្ជមានដែលការផ្តល់ឱ្យទាំងនេះនឹងនាំឱ្យទទួលបានផលិតភាពនិងប្រាក់ចំណូលកាន់តែខ្ពស់។ វិធីសាស្ត្ររបស់ក្រសួងដែលមាននៅក្នុងសេចក្តីព្រាងច្បាប់កាលពីថ្ងៃទី៣០ខែតុលា ឆ្នាំ២០១១ ក្នុងការបង្កើតតំបន់អភិវឌ្ឍន៍កសិកម្ម ជាករណីមួយនៅក្នុងចំណុចនេះ។ នេះជាឧទាហរណ៍មួយ អំពីអ្វីដែលកសិករប្រាថ្នាចង់បាន ក៏ដូចជាអ្វីដែលធ្វើឱ្យទំនាក់ទំនងរវាងក្រសួងនិងកសិករកាន់តែមានភាពសុខដុមរមនីយកម្មនៅក្នុងតំបន់អភិវឌ្ឍន៍កសិកម្ម ជាជាងការដែលមានចែងនៅក្នុងសេចក្តីព្រាងច្បាប់បច្ចុប្បន្ននេះ។ |

## ២.ការស្នើសុំឲ្យមានការពន្យល់បន្ថែម

២.១ តាមប្រភពអន្តរជាតិមួយ យើងខ្ញុំយល់ថា សេចក្តីព្រាងច្បាប់បច្ចុប្បន្ននេះ បានយកគម្រូខ្លះតាមច្បាប់ស្តីពីដីកសិកម្មឆ្នាំ២០០៥របស់ប្រទេសកូស្សូវ៉ូ? យើងខ្ញុំសូមជម្រាបជូនថា ច្បាប់ប្រទេសកូស្សូវ៉ូ បានដាក់ចេញនូវការត្រួតត្រាយ៉ាងខ្លាំងទៅលើកសិករនិងដាក់ចេញនូវទោសប្បញ្ញត្តិដល់កសិករ ហើយ តើក្រសួងបានដឹងអំពីបទពិសោធន៍របស់ប្រទេសកូស្សូវ៉ូ ថាតើការអនុវត្តច្បាប់នេះ មានលក្ខណៈយ៉ាងដូចម្តេចដែរ?

២.២ សុំពន្យល់បន្ថែម អំពីទំនាក់ទំនងរវាង "ធនធានដីកសិកម្ម" និង "តំបន់អភិវឌ្ឍន៍កសិកម្ម" ដីដែលនឹងត្រូវចាត់ថ្នាក់ និងដីដែលនឹងត្រូវចុះបញ្ជី។ យើងខ្ញុំយល់ថា ក្នុងន័យនេះ ធនធានដីកសិកម្ម ហាក់ដូចជាបញ្ញត្តិជាមូលដ្ឋានចំបង ហើយវាហាក់ដូចជាមានការពាក់ព័ន្ធទាំងស្រុងទៅលើរាល់ប្រភេទដីកសិកម្ម គ្រប់ប្រភេទ។ បន្ទាប់មក តំបន់អភិវឌ្ឍន៍កសិកម្ម ត្រូវបានបង្កើតចេញពីធនធានដីកសិកម្មនោះ។ បន្ទាប់មកទៀត ក្នុងចំណោមតំបន់អភិវឌ្ឍន៍កសិកម្មទាំងអស់ និង ធនធានដីកសិកម្មទាំងអស់ដែលមិននៅក្នុងតំបន់អភិវឌ្ឍន៍កសិកម្ម ត្រូវបានចាត់ថ្នាក់ និងជាចុងក្រោយ ត្រូវធ្វើការចុះបញ្ជី។ ការចុះបញ្ជី ហាក់ដូចជា គ្របដណ្តប់ទៅលើធនធានដីកសិកម្មទាំងអស់។

២.៣ យើងខ្ញុំសង្កេតឃើញថា ការពន្យល់ន័យនៃពាក្យ "ដីកសិកម្ម" និង "ធនធានដីកសិកម្ម" មានន័យស្ទើរតែដូចគ្នា តើមានកន្លែងណាដែលមិនដូចគ្នាដែរឬទេ?

២.៤ ហេតុអ្វីនិយមន័យនៃពាក្យ "ដីកសិកម្ម" មានបញ្ចូល "រចនាសម្ព័ន្ធ ឬហេដ្ឋារចនាសម្ព័ន្ធ បម្រើដល់វិស័យកសិកម្ម" ខណៈនិយមន័យនៃ ពាក្យ "ធនធនដីកសិកម្ម" មិនមានបញ្ចូល?

២.៥ តើការចុះបញ្ជីដីកសិកម្មនេះ សម្រាប់តែដី ឬតំបន់ដែលមានទំហំធំខ្លាំង ឧទាហរណ៍ដូចជា តំបន់អភិវឌ្ឍន៍កសិកម្ម និងសម្បទានដីសេដ្ឋកិច្ច? ប្រសិនបើដូច្នេះ យើងខ្ញុំស្នើសុំឱ្យលុបចោលឬចែងមាត្រា៣០.២ ឡើងវិញ។ នេះគឺដោយសារតែមាត្រា៣០.២នេះ ហាក់ដូចជាការអំពាវនាវឱ្យក្រសួងចុះបញ្ជីក្បាលដីទាំងអស់ ដោយដំបូងត្រូវចុះបញ្ជីដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដែលបានបង្ហាញនៅលើឯកសារចុះបញ្ជីរបស់ក្រសួងរៀបចំដែនដីជាដីកសិកម្ម។

២.៦ តើចក្ខុវិស័យរបស់ក្រសួងទៅថ្ងៃមុខតម្រូវឱ្យគ្រួសារកសិករភាគច្រើនផ្តុំគ្នាទៅជាតំបន់អភិវឌ្ឍន៍កសិកម្ម?

២.៧ តើការបង្រួមក្បាលដីនឹងកើតមានឡើងនៅក្នុងតំបន់អភិវឌ្ឍន៍កសិកម្ម ឬនៅកន្លែងផ្សេងទៀតដែរឬទេ? ប្រសិនបើមាន តើវានឹងកើតឡើងដោយឈរលើមូលដ្ឋានស្ម័គ្រចិត្តទាំងស្រុងដែរ ឬទេ?

២.៨ តើដីបម្រុងនៅក្នុង មាត្រា៣៧ និង៣៨ នៃសេចក្តីព្រាងច្បាប់នេះ សំដៅទៅលើភាពដូចគ្នាទៅនឹងដីដែលមានចែងក្នុងច្បាប់ភូមិបាលមាត្រា ២៥ និងអនុក្រឹត្យ៨៣ មាត្រា៤ ដែរឬទេ?

**៣.សេចក្តីសន្និដ្ឋាន**

អង្គការសង្គមស៊ីវិលនិងបណ្តាញអភិវឌ្ឍន៍សន្តិសុខ និងសុវត្ថិភាពស្បៀងនៅកម្ពុជានៃវេទិកាននៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជាសូមចូលរួមយោបល់តែ១១មាត្រានិង១ជំពូកគឺជំពូកទី១០។

យើងខ្ញុំជឿជាក់ថា ដើម្បីតំណាងឲ្យសមាជិកភាគច្រើនបានលើកឡើង យើងខ្ញុំចង់ឃើញមានការកែសម្រួលនៃសេចក្តីព្រាងច្បាប់នេះក្នុងកម្រិតអប្បបរមាមួយតាមដែលអាចធ្វើទៅបានដើម្បីឱ្យយើងខ្ញុំបានបន្តការចូលរួមនិងគាំទ្រដល់សេចក្តីព្រាងច្បាប់នេះបន្តទៅមុខទៀត និងដើម្បីជម្រុញឲ្យសមាជិកបណ្តាញក៏ដូចជាអង្គការផ្សេងៗទៀតក្នុងការគាំទ្រទៅលើសេចក្តីព្រាងច្បាប់នេះ។

ភ្នំពេញ ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៧
រៀបចំដោយ

**បណ្តាញអភិវឌ្ឍន៍សន្តិសុខ និងសុវត្ថិភាពស្បៀងនៅកម្ពុជា**
**នៃវេទិកាអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា**